សំណួរ និងចម្លើយ

សំណួរ ៖ តើហេតុអ្វីមានការវាយតម្លៃច្រើន?

ចម្លើយ ៖ WAC 388-310-1450 ចែងថា ឪពុកម្តាយក្នុងការមានផ្ទៃពោះដល់ផ្លូវការងារត្រូវតែចូលរួមក្នុងការវាយតម្លៃជាមួយអ្នកឯកទេសបុគ្គលិកសង្គមនៃក្រសួងសេវាកម្មសង្គម និងសុខាភិបាលដើម្បីកំណត់សកម្មភាពមួយណាដែលសាកសមបំផុតសម្រាប់តម្រូវការរបស់អ្នក ។ ការវាយតម្លៃទាំងនេះនឹងត្រូវធ្វើឡើងនៅចំណុចខុសៗគ្នាក្នុងពេលមានផ្ទៃពោះ (ពេលដែលក្រសួងដឹងថាអ្នកមានផ្ទៃពោះ ឬមានកូនអាយុក្រោមមួយឆ្នាំ និងក្រោយពីសម្រាល) ដើម្បីកំណត់ការផ្លាស់ប្តូរនានាក្នុងស្ថានភាពគ្រួសាររបស់អ្នក និងដើម្បីប្រាកដថាសកម្មភាពដែលតម្រូវឲ្យធ្វើនៅតែសមរម្យ ។ ឧទាហរណ៍ តម្រូវការរបស់អ្នកក្នុងត្រីមាសទីបីអាចខុសគ្នាខ្លាំងពីតម្រូវការរបស់អ្នកក្រោយអ្នកសម្រាល ។ ពួកយើងចង់ធានាថាតម្រូវការ WorkFirst របស់អ្នកបន្តបំពេញតម្រូវការរបស់អ្នក ។

សំណួរ ៖ តើមានអ្វីកើតឡើង បើខ្ញុំមិនបានចូលរួមការណាត់ជួបវាយតម្លៃ?

ចម្លើយ ៖ បើអ្នកមិនបានចូលរួមក្នុងការវាយតម្លៃ ពួកយើងនឹងបន្តជាមួយដំណើរការត្រឹមត្រូវដើម្បីកំណត់ថាតើអ្នកមានមូលហេតុសមរម្យសម្រាប់ការមិនចូលរួម ឬអត់ ។ បើអ្នកមិនមានមូលហេតុត្រឹមត្រូវទេ អ្នកនឹងត្រូវដាក់ពិន័យ និងជំនួយសាច់ប្រាក់ WorkFirst របស់អ្នកនឹងត្រូវបានកាត់បន្ថយ ។

សំណួរ ៖ តើមានតែខ្ញុំម្នាក់ប៉ុណ្ណោះដែលតម្រូវឲ្យចូលរួមក្នុងការវាយតម្លៃមែនទេ?

ចម្លើយ ៖ ឪពុក ឬម្តាយនីមួយៗដែលទទួលជំនួយសាច់ប្រាក់ TANF ត្រូវតែចូលរួមក្នុងការវាយតម្លៃដើម្បីស្គាល់តម្រូវការគ្រួសារ ។ តម្រូវការការចូលរួម WorkFirst នឹងត្រូវផ្អែកលើលទ្ធផលនៃការវាយតម្លៃនេះ ។ បើឪពុកម្តាយទាំងពីរនាក់នៅផ្ទះ ឪពុក ឬម្តាយ (ប៉ុន្តែមិនមែនទាំងពីរនាក់) អាចយកការលើកលែងទារកនៅពេលណាមួយ ។

សំណួរ ៖ តើខ្ញុំនឹងដឹងយ៉ាងដូចម្តេច បើដល់ពេលវេលាធ្វើការវាយតម្លៃ?

ចម្លើយ ៖ ក្នុងករណីជាច្រើន អ្នកឯកទេសបុគ្គលិកសង្គម ឬអ្នកគ្រប់គ្រងសំណុំរឿងរបស់អ្នកនឹងផ្ញើឲ្យអ្នកនូវលិខិតណាត់ជួប ។ បើអ្នកមិនអាចមកការិយាល័យ ពួកគេអាចជួបនៅផ្ទះរបស់អ្នក ឬបំពេញការវាយតម្លៃតាមទូរស័ព្ទ ។ ទាក់ទងអ្នកឯកទេសបុគ្គលិកសង្គមរបស់អ្នកសម្រាប់ព័ត៌មានបន្ថែមលើផ្នែកទាំងនេះ ។

អ្នកគ្រប់គ្រងសំណុំរឿង WorkFirst _____

ទូរស័ព្ទ _____

បុគ្គលិកសង្គម WorkFirst _____

ទូរស័ព្ទ _____

Washington State
Department of Social & Health Services

Transforming lives

DSHS 22-1262 CA (Rev. 7/15)

ការមានផ្ទៃពោះដល់ផ្លូវការងារ

តើខ្ញុំអាចសង្ឃឹមអ្វីខ្លះ ពេលដែលខ្ញុំជាផ្នែកនៃការមានផ្ទៃពោះដល់ផ្លូវការងារ?

តើនរណាជាផ្នែកនៃការមានផ្ទៃពោះដល់ផ្លូវការងារ?

អ្នកជាផ្នែកនៃការមានផ្ទៃពោះដល់ផ្លូវការងារ បើអ្នក

ទទួលបានជំនួយសាច់ប្រាក់ TANF (ជំនួយបណ្តោះអាសន្ន

ដល់គ្រួសារក្រីក្រ) និងអ្នកមានផ្ទៃពោះ ឬថែទាំកូនដែល

មានអាយុក្រោម 12 ខែ ។

តើអ្វីជាគោលដៅនៃការមានផ្ទៃពោះដល់ផ្លូវការងារ?

កសាងគ្រួសារដែលមានសុខភាពល្អ

ជួយគ្រួសារចូលរួមក្នុងសកម្មភាព WorkFirst ដោយជួយពួកគេបំពេញ
តម្រូវការវេជ្ជសាស្ត្រ និងតម្រូវការផ្សេងទៀតរបស់គ្រួសារ។

ជួយគ្រួសារដើម្បីក្វាយជាម្ចាស់ការលើខ្លួនឯង

មានជំហានជាច្រើនក្នុងការមានផ្ទៃពោះដល់ផ្លូវការងារ ។ អ្នកអាចឆ្លងកាត់
ពួកវាទាំងអស់ ឬតែជំហានខ្លះប៉ុណ្ណោះ ។ វានឹងផ្អែកលើជំណាក់កាល
ណានៃការមានផ្ទៃពោះដែលអ្នកស្ថិតនៅ ។

បើអ្នកទើបតែទទួលបានកម្មវិធី TANF ជំហានដំបូងរបស់អ្នកនឹងជា
ជំណើរការវាយតម្លៃគ្រប់ជ្រុងជ្រោយ ។

ការវាយតម្លៃការមានផ្ទៃពោះដល់ការងារ

ជំហានបន្ទាប់របស់អ្នកគឺ ចូលរួមក្នុង និងបំពេញការវាយតម្លៃការមានផ្ទៃពោះដល់
ការងារជាមួយអ្នកឯកទេសបុគ្គលិកសង្គម WorkFirst ។

ការវាយតម្លៃនឹង ៖

- ស្គាល់តម្រូវការ ភាពខ្លាំង និងរបាំងដែលអាចមានរបស់គ្រួសារអ្នក
- ស្គាល់សេវាកម្មដែលអ្នកអាចមានសិទ្ធិទទួលបាន ខណៈដែរអ្នកស្ថិតក្នុងការ
  មានផ្ទៃពោះដល់ផ្លូវការងារ
- កំណត់ការចូលរួមដែលតម្រូវឲ្យមានរបស់អ្នក និងស្គាល់សកម្មភាព WorkFirst
  សមរម្យ

ការចូលរួម WorkFirst ក្នុងត្រីមាសទីមួយ និងទីពីរ

បើអ្នកស្ថិតក្នុងត្រីមាសទីមួយ
ឬទីពីរ (បីទៅប្រាំមួយខែ) នៃការ
មានផ្ទៃពោះអ្នកនឹងត្រូវបាន
តម្រូវឲ្យចូលរួមពេញម៉ោង ឬ
ស្ទើរតែពេញម៉ោងតាមតែអាចធ្វើ
បានក្នុងសកម្មភាព WorkFirst ។
ការចូលរួមពេញម៉ោងគឺពី 32-40
ម៉ោងក្នុងមួយសប្តាហ៍ ។

លទ្ធផលនៃការវាយតម្លៃគ្រប់ជ្រុងជ្រោយ និងការវាយតម្លៃការមានផ្ទៃពោះដល់
ការងារនឹងកំណត់រយៈពេលប៉ុន្មានដែលអ្នកត្រូវចូលរួម ។

ការចូលរួម WorkFirst ក្នុងត្រីមាសទីបី

ផ្អែកលើលទ្ធផលនៃការវាយតម្លៃរបស់អ្នក ពួកយើងនឹងកំណត់ថា
តើអ្នកជា ៖

- អ្នកចូលរួម WorkFirst
  ដោយស្ម័គ្រចិត្ត ឬ
- អ្នកចូលរួម WorkFirst
  ដែលតម្រូវដោយច្បាប់ ឬ
- មានសិទ្ធិជ្រើសរើសមិនចូលរួមក្នុង
  សកម្មភាព WorkFirst ។

ការចូលរួម WorkFirst សម្រាប់ឱពុកម្តាយមានកូនទើបនឹងកើត ដល់អាយុ 12 ខែ

ក្រោយពីអ្នកសម្រាល អ្នកត្រូវតែបំពេញការវាយតម្លៃការមានផ្ទៃពោះដល់
ការងារ ។

ការវាយតម្លៃនេះនឹងកំណត់កម្រិតចូលរួម WorkFirst របស់អ្នក ។ អ្នកអាច
ត្រូវបាន ៖

- ចាត់ទុកជាអ្នកចូលរួម WorkFirst ដោយស្ម័គ្រចិត្ត
- ចាត់ទុកជាអ្នកចូលរួម WorkFirst ដែលតម្រូវដោយច្បាប់
- អាចជ្រើសរើសការលើកលែងទារក (អ្នកអាចប្រើការលើកលែងនេះដល់
  365 ថ្ងៃ ឬ 12 ខែក្នុងមួយជីវិតរបស់អ្នក មុនថ្ងៃកំណើតមួយឆ្នាំ
  របស់កូនអ្នក ។)

បើអ្នកមានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់ការលើកលែងទារក អ្នកអាចជ្រើសរើស
មិនចូលរួមក្នុងសកម្មភាព WorkFirst ។ ដើម្បីមានគុណសម្បត្តិគ្រប់គ្រាន់
អ្នកត្រូវតែចូលរួមក្នុងការវាយតម្លៃដែលតម្រូវឲ្យមាន ។

WAC 388-310-1450

បើអ្នកមានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់ការលើកលែងទារក អ្នកអាចជ្រើស
រើសមិនចូលរួមក្នុងសកម្មភាព WorkFirst ។ ដើម្បីមានគុណសម្បត្តិគ្រប់
គ្រាន់ អ្នកត្រូវតែចូលរួមក្នុងការវាយតម្លៃដែលតម្រូវឲ្យមាន ។

គោលដៅរបស់យើងគឺដើម្បីកសាងគ្រួសារដែលមានសុខភាពល្អ មិនមែន
ដាក់ពិន័យពួកគេទេ ប៉ុន្តែអ្នកត្រូវតែធ្វើផ្នែករបស់អ្នក និងចូលរួមក្នុងការ
មានផ្ទៃពោះដល់ផ្លូវការងារដូចបានតម្រូវឲ្យធ្វើ ។